# ជួបជាមួយម្ចាស់អាជីវកម្មដែលទទួលបានកម្ចីដែលមានការធានាពី CGCC
## Meet the Business Owner Who Received a Credit Guarantee from CGCC



លោក សុខ ណាឡែន ម្ចាស់អាជីវកម្ម កសិដ្ឋានចិញ្ចឹមជ្រូកប្រើប្រាស់ឡជីវឧស្ម័នខ្នាតធំ ដែលមានទីតាំងនៅ ភូមិក្រាំងសៀម ឃុំសេដ្ឋី ខេត្តកំពង់ឆ្នាំង

KH នៅក្នុងឆ្នាំ ២០១៤ ខ្ញុំបាទបានចាប់ផ្តើមអាជីវកម្ម កសិដ្ឋានចិញ្ចឹមជ្រូកមួយនេះឡើង។ ដំបូងឡើយ កសិដ្ឋាននេះគឺជាកសិដ្ឋានចិញ្ចឹមជ្រូកកូនរហូតដល់ឆ្នាំ២០១៩ កសិដ្ឋានមួយនេះបានប្រែក្លាយទៅជាកសិដ្ឋានចញ្ចឹមជ្រូកសាច់។

ពេលចាប់ផ្តើមអាជីកម្មកសិដ្ឋានចិញ្ចឹមជ្រូកនេះដំបូង ខ្ញុំប្រឈមនឹងបញ្ហាសំខាន់២គឺ បញ្ហាបច្ចេកទេស និងបញ្ហាទុនបង្វិល។ បច្ចេកវិទ្យាប្រែប្រួលយ៉ាងឆាប់រហ័សពីមួយឆ្នាំទៅមួយឆ្នាំ ដែលតម្រូវឲ្យម្ចាស់អាជីវកម្មមានទុនបង្វិលគ្រប់គ្រាន់។ ចំពោះកសិដ្ឋានរបស់ខ្ញុំ តាមស្តង់ដារបច្ចេកទេស គឺតម្រូវឲ្យមានឡជីវឧស្ម័នដែលការពារបរិស្ថានជុំវិញកសិដ្ឋានដូចជា ការពារការបំភាយផ្សែងពុល និងការពារក្លិនមិនល្អនានា។ មិនតែប៉ុណ្ណោះ ឡជីវឧស្ម័នអាចឱ្យយើងកែច្នៃកាកសំណល់ មកប្រើប្រាស់ឡើងវិញបាន។ ជាសំណាងល្អមជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ (BTIC) បានផ្តល់ជំនួយបច្ចេកទេស ក្នុងការកែច្នៃ និងបង្កើតឡជីវឧស្ម័នសម្រាប់កសិដ្ឋានចិញ្ចឹមជ្រូករបស់ខ្ញុំ។ យ៉ាងណាក៏ដោយ កង្វះទុនគឺជាបញ្ហាប្រឈមមួយទៀតសម្រាប់ខ្ញុំ។ តាមរយៈភាពជាដៃគូសហការរបស់ CGCC BTIC បានណែនាំខ្ញុំអំពីកម្ចីដែលមានការធានា ដោយមិនចាំបាច់មានទ្រព្យធានា។ ជាមួយការធានាឥណទានពី CGCC ខ្ញុំក៏ទទួលបានកម្ចីអាជីវកម្មពីធនាគារកាណាឌីយ៉ា តាមអ្វីដែលខ្ញុំបានស្នើសុំ និងទាន់ពេលវេលាដោយមិនចាំបាច់មានទ្រព្យធានា។ កម្ចីដែលមានការធានាពី CGCC គឺជាទុនបង្វិល ដែលអាចឲ្យខ្ញុំបន្តការសាងសង់ឡជីវឧស្ម័នថ្មី ដើម្បីទ្រទ្រង់កសិដ្ឋានចិញ្ចឹមជ្រូករបស់ខ្ញុំ។

ការទទួលបានកម្ចីដែលមានការធានាពី CGCC គឺអាស្រ័យទៅលើសក្តានុពលនៃអាជីវកម្មរបស់ខ្ញុំ ពោលគឺលទ្ធភាពនៃការរីកចម្រើនទៅមុខ ការកសាងការថែទាំប្រវត្តិឥណទានឲ្យបានល្អ ក៏ដូចជាការបំពេញឯកសារតម្រូវដែលអាចបញ្ជាក់ពីភាពចាំបាច់ក្នុងការប្រើប្រាស់កម្ចីសម្រាប់អាជីវកម្មរបស់ខ្ញុំ។ ម្ចាស់អាជីវកម្មដទៃទៀត ដែលមានតម្រូវការទុន ប៉ុន្តែខ្វះទ្រព្យធានា ក៏អាចស្វែងរកការធានាឥណទានពី CGCC តាមរយៈគ្រឹះស្ថានធនាគារ ឬមីក្រូហិរញ្ញវត្ថុជាដៃគូរបស់ CGCC បានដែរ៕

EN In 2014, I started this pig farm business. Initially, this farm was a farm raising piglets, but in 2019 it was transformed into a bigger farm supplying meat.

When starting this business, I faced two main challenges: technical and financial challenges. Technology changes rapidly from one year to another requiring businesses to have enough capital to keep up with it. Based on the technical standard, my farm must be equiped with a biogas plant to protect the surrounding environment by reducing emission of toxic fumes and odors. The biogas plant can also recycle waste and other residuals. Fortunately, Biogas Technology and Information Center (BTIC) provided technical support to me to restore and set up a biogas plant for my farm. However, I need more capital. With the cooperation with CGCC, BTIC introduced me to a way to access non-collateralized loans with credit guarantees. With CGCC's guarantee, I could get a business loan from Canadia Bank as requested on time without collateral. The guaranteed loan served as my working capital, which allowed me to continue building a new biogas plant to support my pig farm.

Obtaining guaranteed loans depends on the potential of my business, namely the possibility of growth, a good credit history, and the required documents that prove the need for the loan for my business. Other business owners who require additional capital, but no collateral can also seek for credit guarantee from CGCC through CGCC's PFIs.

